terre des hommes
stops child exploitation

# អង្គការដែលដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជា ( TdH NL ) បានរៀបចំ វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពស្តីពី “ការថែទាំលើការប៉ះទង្គិចផ្លូវចិត្ត” ដើម្បីជាប្រយោជន៍ដល់កុមារដែលរងផលប៉ះពាល់ពីការ រំលោភបំពាន និងការកេងប្រវ័ញ្ច

អង្គការដែនដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជា **(TdH NL)** ជាអង្គការអន្តជាតិមួយដែលធ្វើការលើការ ការពារសិទ្ធកុមារ បានដឹងនាំរៀបចំវគ្គបណ្តុះបណ្តាលកសាង សមត្ថភាពដល់ អង្គការដៃគូរចំនួន៧ ដែលមានទីតាំងនៅរាជធានីភ្នំពេញនិងខេត្តសៀមរៀប។ ហើយវគ្គបណ្តុះបណ្តាលនេះក៏មាន ការចូលរួមពីមន្ត្រីរាជរដ្ឋាភិបាលផងដែរ ។ វគ្គបណ្តុះបណ្តាលនេះនិងចាប់ផ្តើមនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២២ នៅមជ្ឍមណ្ឌលដាយកូនៀរភ្នំពេញ និងមានការចូលរួមបើកវគ្គបណ្តុះ បណ្តាលដោយ លោកស្រី **មុំ ចាន់ដានី** ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទានៃរាជធានីភ្នំពេញ។

គោលបំណងនៃការបណ្តុះបណ្តាលនេះគឺដើម្បីកសាងសមត្ថភាពរបស់អ្នកផ្តល់សេវាដែលធ្វើការជាមួយកុមារដែលរងផលប៉ះពាល់ដោយការរំលោភផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទ ដើម្បីរួមបញ្ចូលវិធីសាស្ត្រថែទាំលើការប៉ះទង្គិចផ្លូវចិត្ត។ ខ្លឹមសារក្នុងការរបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងដោយមានការសហការជាមួយអ្នកជំនាញការពារកុមារអន្តរជាតិ។ បន្ទាប់ពីការបណ្តុះបណ្តលនេះ អង្គការដែនដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជា **(TdH NL)** និងមានផែនការរបង្វឹកបន្ថែមប្រចាំត្រីមាស ដល់អង្គការដៃគូរ និងនាយកដ្ឋានរដ្ឋាភិបាលដែលពាក់ព័ន្ធ។

ការថែទាំការប៉ះទង្គិចផ្លូវចិត្តជាវីធីសាស្រ្តមួយដែលសំរាប់អ្នកធ្វើការសង្គមយល់ និងចេះសម្របខ្លួនទៅតាមបទពិសោធន៍របស់ជនរងគ្រោះ និងឥទ្ធិពលនៃការប៉ះទង្គិចទៅលើអារម្មណ៍ រូបរាងកាយ និងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ នៅពេលធ្វើការជាមួយកុមារដែលមានការប៉ះទង្គិច ផ្លូវចិត្ត អ្នកផ្តល់សេវាត្រូវយល់អំពីផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្ត និងត្រូវដឹងថាការប្រើប្រាស់ ភាសា និងទង្វើមួយចំនួនអាចជាការបន្ថែមការប៉ះទង្គិចផ្លូវចិត្តថែមទៀត។

ការព្យាបាលការប៉ះទង្គិចផ្លូវចិត្តទាមទារអោយមានការយកចិត្តទុកដាក់ពីបរិស្ថានជុំវិញ ដើម្បីកសាងទំនុកចិត្ត និងសុវត្ថិភាពដល់កុមារដើម្បីជាការបើកផ្លូវដល់ការជាសះស្បើយឡើងវិញ។

អ្នកស្រី **Zoe DE MELO** ប្រធានគ្រប់គ្រងគម្រោងប្រចាំនៅកម្ពុជាបានមានប្រសាសន៍ថា វិធីសាស្រ្តនេះជាវិធីសាស្រ្តដែលថ្មីនៅកម្ពុជា ហើយក៏ជាមោទនភាពក្នុងការរៀបចំវគ្គបណ្តុះបណ្តាលដល់មានសារៈសំខាន់នេះឡើង។ តាមរយៈវគ្គបណ្តុៈបណ្តាលនេះ អង្គការដែនដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជា **(TdH NL)** ផ្តោតទៅលើគុណភាពនៃការថែទាំនៅក្នុងប្រទេសកម្ពុជា តាមរយៈការគាំទ្រដល់ រាជរដ្ឋាភិបាល និង អង្គការដែលផ្តល់សេវា ដើម្បីប្រើប្រាស់ វាជាស្តង់ដាមួយសម្រាប់អ្នកធ្វើការងារ

សង្គម។

អង្គការដែនដីមនុស្ស- ហូឡង់ដ៏ប្រចាំកម្ពុជា **(TdH NL)** បានបង្កើតឡើងនៅក្នុងប្រទេស កម្ពុជា តាំងពីឆ្នាំ២០០៧។ អង្គការ **(TdH NL)** មានទស្សនៈវិស័យលើការការពារកុមារពីការកេងប្រវ័ញ្ចនិង ជួយកុមារអោយចាកចេញផុតពីការកេងប្រវ័ញ្ចគ្រប់ទម្រង់ និងធានាថាកុមារទទួល បានការអភិវឌ្ឍន៍ពេញលេញ និងប្រកបដោយសុវត្ថិភាព។ អង្គការ **(TdH NL)** អនុវត្តគម្រោងតាមរយៈ ការសហការជាមួយអង្គការដៃគូរ ជាពិសេសនៅតំបន់អាស៊ី និង អាហ្វ្រិកខាងកើត។

សម្មសភាពអ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលមានដូចជា៖ នាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា និង នាយកដ្ឋានកិច្ចការនារី និងគណៈកម្មាធិការប្រឆាំងការជួញដូរ (PCCT) ខេត្តសៀមរាប អង្គការជីវិតនៅកម្ពុជា (This Life Cambodia) អង្គការគ្រួសារថ្មី (Krousar Thmey) សហាគមន៍ (Hard Places Community) អង្គការក្តីសង្ឃឹមយុត្តិធម៌ (Hope for Justice) គម្រោងសេរីភាព (Auscam) អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការសម្រេចសុបិន្ត (Feeding Dreams) ៕